# វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី ២៦ ខែ តុលា ២០១៨**

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះ គឺ៖

- ចំណូលពន្ធរបស់កម្ពុជាមានការកើនឡើង ១៧,៥% គិតតាំងពីដើមឆ្នាំមកដល់បច្ចុប្បន្ន
- ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី រវាងសហភាពអឺរ៉ុប និងប្រទេសសិង្ហបុរី
- លោក ត្រាំ បានធ្វើការរិះគន់ចំពោះទេសាភិបាលធនាគារកណ្តាល

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះ គឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗ នៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារ បណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីធានាថាការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះ មានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តនៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ចំណូលពន្ធរបស់កម្ពុជាមានការកើនឡើង ១៧,៥% គិតពីដើមឆ្នាំមកដល់បច្ចុប្បន្ន

យោងទៅលើរបាយការណ៍បច្ចុប្បន្នភាពរបស់ទំព័រហ្វេសបុកនៃអគ្គនាយកដ្ឋានពន្ធដារ៖ កម្ពុជាបានប្រមូលចំណូលពីពន្ធដារចំនួន១,៧ប៊ីលានដុល្លារ ក្នុងអំឡុងពេលប្រាំបួនខែដំបូងនៃឆ្នាំ ២០១៨ គឺកើនឡើងច្រើនជាង១៧,៥% បើធៀបទៅនឹងប្រាំបួនខែដំបូងដូចគ្នាក្នុងឆ្នាំ ២០១៧។

ការប្រមូលពន្ធដារក្នុងខែកញ្ញា សរុបមានចំនួន១៨៨លានដុល្លារ កើនឡើង ៤២,១% បើប្រៀបធៀបទៅនឹងខែកញ្ញា ដូចគ្នាក្នុងឆ្នាំ ២០១៧ ។

យោងទៅលើប្រសាសន៍របស់លោក គង់ វិបុល អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ៖ អគ្គនាយកដ្ឋានពន្ធដារនឹងមិនមានបញ្ហាក្នុងការប្រមូលពន្ធដារក្នុងឆ្នាំនេះ ឲ្យទៅតាមគោលដៅដែលមានប្រមាណ១,៩ប៊ីលានដុល្លារនោះទេ ដោយការអនុវត្តយុទ្ធសាស្ត្រប្រមូលចំណូលរយៈពេលមធ្យមឆ្នាំ២០១៤-២០១៨ ត្រូវបានធ្វើឡើងប្រកបដោយប្រសិទ្ធភាព។ ការពង្រីកការខិតខំប្រឹងប្រែងក្នុងការប្រមូលចំណូលពន្ធដារតាមបណ្តាខេត្តគឺជាកិច្ចការសំខាន់ ក្នុងនោះដែរ ការពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់មន្ត្រីពន្ធដារទៅលើការអនុលោមទៅតាមច្បាប់ត្រូវបានធ្វើឡើង ដើម្បីជម្រុញអោយក្រុមហ៊ុនកាន់តែច្រើនធ្វើការចុះបញ្ជី និងចូលរួមក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ។

### តារាងប្រចាំសប្តាហ៍៖ ការវិនិយោគឯកជនតាមវិស័យ

តារាងប្រចាំសប្តាហ៍នេះបង្ហាញពីការផ្លាស់ប្តូរនៃការវិនិយោគវិស័យឯកជនដែលត្រូវបានអនុម័តក្នុងត្រីមាសទី១ នៃឆ្នាំ ២០១៦, ២០១៧ និង២០១៨ យោងតាមរបាយការណ៍របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ ការវិនិយោគសរុបបានប្រែប្រួលគួរឲ្យកត់សម្គាល់នៅចន្លោះរយៈពេលខាងលើ។

ការវិនិយោគក្នុងវិស័យកសិកម្មនៅក្នុងត្រីមាសដំបូងនៃឆ្នាំ ២០១៨ បានកើនឡើងដល់២១០លានដុល្លារ គឺពី៣៨លានដុល្លារក្នុងរយៈពេលដូចគ្នានៅក្នុងឆ្នាំ២០១៦ ដែលកើនឡើងប្រមាណ៤៥២%។ ការកើនឡើងនេះ ភាគច្រើនជាការវិនិយោគនៅក្នុងផ្នែករោងម៉ាស៊ីនកិនស្រូវ។

ការវិនិយោគវិស័យសេវាកម្ម និងទេសចរណ៍ បានធ្លាក់ចុះយ៉ាងខ្លាំងពី ៦៤២លានដុល្លារក្នុងឆ្នាំ២០១៦ មកត្រឹម៤លានដុល្លារក្នុងឆ្នាំ២០១៧ ប៉ុន្តែបានចាប់ផ្តើមកើនឡើងវិញក្នុងឆ្នាំ២០១៨។

ការវិនិយោគក្នុងវិស័យឧស្សាហកម្ម ដែលភាគច្រើនផ្តោតលើការកែច្នៃអាហារ ផលិតផលលោហៈ និងគ្រឿងបន្លាស់យានយន្តនៅថេរ ចន្លោះពី១៣៤លានដុល្លារ, ១១៦លានដុល្លារ និង១៥៤លានដុល្លារនៅក្នុងត្រីមាសទី១ ឆ្នាំ ២០១៦, ២០១៧ និង២០១៨។

### ទុនវិនិយោគតាមវិស័យ (គិតជាលានដុល្លារ)




ប្រភព៖ ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ព័ត៌មាន និងនិន្នាការរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី រវាងសហភាពអឺរ៉ុប និងប្រទេសសិង្ហបុរី

សហភាពអឺរ៉ុប និងប្រទេសសិង្ហបុរី បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី កាលពីថ្ងៃសុក្រកន្លងទៅ ក្រៅពីកិច្ចប្រជុំកំពូល អឺរ៉ុប-អាស៊ី នៃទីក្រុងប្រ៊ុយសែល។

ក្នុងនោះដែរ គណៈអធិបតីនៃប្រទេសអាល្លឺម៉ង់ លោកស្រី អែនជឺឡា មឺឃែល បានលើកសរសើរថា៖ ″យើងអាចបញ្ជាក់ឲ្យច្បាស់ថាពិភពលោកគឺការបង្កើតស្ថានភាព ឈ្នះ-ឈ្នះ″ ហើយលោកស្រីក៏បានលើកឡើងថា នេះជាផលប្រយោជន៍សម្រាប់ទាំងអស់គ្នា។ កិច្ចព្រមព្រៀងនេះចាំបាច់ត្រូវតែមានការអនុម័តដោយសភាអឺរ៉ុបមុនចូលជាធរមាននៅឆ្នាំ២០១៩។

កិច្ចព្រមព្រៀង សិង្ហបុរី ធ្វើឡើងបន្ទាប់ពី សហភាពអឺរ៉ុបបានបោះបង់កិច្ចប្រឹងប្រែងរបស់ខ្លួននៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មជាមួយអាស៊ាននៅឆ្នាំ២០០៩ ដោយសារតែមានការមិនឯកភាពគ្នាជាច្រើន។

## សេដ្ឋកិច្ចសហរដ្ឋអាមេរិក និងទុនបម្រុងសហព័ន្ធ

### លោក ត្រាំ បានធ្វើការរិះគន់ដល់ទេសាភិបាលធនាគារកណ្តាល

លោកប្រធានាធិបតីអាមេរិក ដូណាល់ត្រាំ បានធ្វើការចោទប្រកាន់ដោយផ្ទាល់ទៅកាន់លោក ជេរ៉ូម ប៉ូវែល ចំពោះការធ្វើឲ្យប៉ះពាល់ដល់សេដ្ឋកិច្ចអាមេរិក តាមរយៈការបង្កើនអត្រាការប្រាក់ ដោយលោកបាននិយាយថា ″ខ្ញុំមិនសប្បាយចិត្តជាខ្លាំងជាមួយធនាគារកណ្តាល ដោយសារតែនៅក្នុងអាណត្តិរបស់លោក អូបាម៉ា អត្រាការប្រាក់គឺសូន្យ″។

លោក ត្រាំ បានទទួលស្គាល់ថា ធនាគារកណ្តាលគួរតែធ្វើសកម្មភាពដោយឯករាជ្យ ដោយមិនពឹងផ្អែកទៅលើឥទ្ធិពលនយោបាយ ប៉ុន្តែនោះមិនបានបញ្ឈប់ការបញ្ចេញមតិរិះគន់របស់គាត់ទេ។

បេសកកម្មរបស់ធនាគារកណ្តាលគឺកំណត់អត្រាការប្រាក់ ក្នុងគោលដៅសំខាន់ៗពីរ គឺ៖ បង្កើនភាពមានការងារធ្វើអោយបានច្រើនបំផុត និងទប់ស្កាត់អតិផរណា។ ទោះជាយ៉ាងណាក៏ដោយ លោក ត្រាំ បានលើកយកបញ្ហាតម្លើងអត្រាការប្រាក់ ចំនួន៣

ដងរួចមកហើយរបស់ធនាគារកណ្តាល នៅក្នុងឆ្នាំនេះ ខណៈពេលសេដ្ឋកិច្ចសហរដ្ឋអាមេរិកកំពុងតែមានស្ថានភាពក្តៅគគុក។ ធនាគារកណ្តាលត្រូវបានគេរំពឹងយ៉ាងខ្លាំងថាអាចនឹងមានការតម្លើងអត្រាការប្រាក់ម្តងទៀត នៅមុនបំណាច់ឆ្នាំនេះ។

## ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្តាហ៍ខាងមុខនេះ រួមមាន៖ អត្រាការប្រាក់របស់ប្រទេសជប៉ុន និងចក្រភពអង់គ្លេស, ភាពមានការងារនៅសហរដ្ឋអាមេរិក នឹងអតិផរណានៅអូស្ត្រាលី។

ខាងក្រោមនេះគឺជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និងការអភិវឌ្ឍ ដែលក្រុមការងារនឹងបន្តតាមដាននៅសប្តាហ៍ក្រោយ៖

<u>ថ្ងៃច័ន្ទ ទី២៩ ខែតុលា</u>

- ការលក់រាយនូវទំនិញនៅប្រទេសជប៉ុន ខែកញ្ញា
- ប្រាក់ចំណូល និងការចំណាយរបស់បុគ្គលនីមួយៗ នៅសហរដ្ឋអាមេរិក ខែកញ្ញា

<u>ថ្ងៃអង្គារ ទី៣០ ខែតុលា</u>

- អត្រាភាពគ្មានការងារធ្វើនៅប្រទេសជប៉ុន ខែកញ្ញា
- ការវិនិយោគផ្ទាល់ពីបរទេស របស់ប្រទេសឥណ្ឌូនេស៊ី ខែតុលា
- ផលិតផលក្នុងស្រុកសរុបរបស់ប្រទេសបារាំង គិតត្រឹមត្រីមាសទី៣ ឆ្នាំ២០១៨

<u>ថ្ងៃពុធ ទី៣១ ខែតុលា</u>

- ផលិតកម្មឧស្សាហកម្មរបស់កូរ៉េខាងត្បូង ខែកញ្ញា
- សមាមាត្រការងារនិងការដាក់ពាក្យរកការងាររបស់ប្រទេសជប៉ុន ខែកញ្ញា
- ការសម្រេចចិត្តរបស់ធនាគារជប៉ុនលើអត្រាការប្រាក់
- អតិផរណារបស់ប្រទេសអូស្ត្រាលី ខែកញ្ញា

<u>ថ្ងៃព្រហស្បត្តិ៍ ទី០១ ខែវិច្ឆិកា</u>

- អតិផរណារបស់កូរ៉េខាងត្បូង ខែតុលា
- តុល្យភាពពាណិជ្ជកម្មកូរ៉េខាងត្បូង ខែតុលា
- អតិផរណារបស់ប្រទេសឥណ្ឌូនេស៊ី ខែតុលា
- របាយការណ៍អតិផរណានិងការសម្រេចចិត្ត លើអត្រាការប្រាក់នៃចក្រភពអង់គ្លេស
-

<u>ថ្ងៃសុក្រ ទី០២ ខែវិច្ឆិកា</u>

- ភាពគ្មានការងារធ្វើរបស់សហរដ្ឋអាមេរិក ខែតុលា
- ភាពមានការងារធ្វើនៅកាណាដា ខែតុលា
- សមតុល្យថវិការបស់ប្រទេសបារាំង ខែកញ្ញា